00593489

E188/8

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 25 / 08 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

**សំណុំរឿងលេខ៖** ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

**ដាក់ទៅ៖** អង្គជំនុំជម្រះសាលាដំបូង

**ថ្ងៃដាក់៖** ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០

**ភាគីអ្នកដាក់៖** សហមេធាវីជាតិការពារក្តីលោក **កាំង ហ្គេកអ៊ាវ** ហៅ "ឌុច"

**ភាសាដើម៖** **ភាសាខ្មែរ**

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ស្នើដោយភាគីអ្នកដាក់តម្កល់៖ **សាធារណៈ**

ចំណាត់ថ្នាក់សម្រេចដោយសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ៖

លក្ខន្តិកៈនៃចំណាត់ថ្នាក់៖

ការពិនិត្យចំណាត់ថ្នាក់បណ្តោះអាសន្នឡើងវិញ៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿងនិងឯកសារ៖

ហត្ថលេខា៖

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 24 / 08 / 2010
ម៉ោង (Time/Heure) : 14 : 50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

---

**សេចក្តីជូនដំណឹងរបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ របស់អង្គជំនុំជម្រះសាលាដំបូង**

---

| **អ្នកដាក់ឯកសារ៖** | **អ្នកទទួលឯកសារ៖** |
|---|---|
| **សហមេធាវីការពារក្តីជនជាប់ចោទ** | **អង្គជំនុំជម្រះតុលាការកំពូល** |
| **កាំង ហ្គេកអ៊ាវ** ហៅ "ឌុច" | ចៅក្រម **គង់ ស្រ៊ឹម** ប្រធាន |
| មេធាវី **ការ សាវុត្ថ** | ចៅក្រម **Motoo NOGUCHI** |
| មេធាវី **កង ឫទ្ធារី** | ចៅក្រម **សោម សិរីវឌ្ឍ** |

ចៅក្រម A. KLONOWIECKA-MILART
ចៅក្រម ស៊ិន រិទ្ធ
ចៅក្រម C.N.JAYASIINGHE
ចៅក្រម យ៉ា ណារិន

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម ធូ មណី

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង
លោក Andrew CAYLEY

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

| | | |
|---|---|---|
| មេធាវី គង់ ពិសី | មេធាវី Silke STUDZINSKY | មេធាវី Annie DELAHAIE |
| មេធាវី ហុង គឹមសួន | មេធាវី Martine JACQUIN | មេធាវី Elizabeth RABESANDRATANA |
| មេធាវី យុង ផានិត | មេធាវី Philippe CANNONE | មេធាវី Karim KHAN |
| មេធាវី គីម ម៉េងឃី | មេធាវី Pierre Olivier SUR | មេធាវី Fabienne TRUSSES-NAPROUS |
| មេធាវី ម៉ុច សុវណ្ណារី | មេធាវី Alain WERNER | មេធាវី Christine MARTINEAU |
| មេធាវី ទី ស្រីនណា | មេធាវី Brianne McGONIGLE | |

# សេចក្តីផ្តើម

១. សហមេធាវី ដាក់សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខនេះ ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី២៦ ខែ កក្កដា ឆ្នាំ ២០១០ ("សាលក្រម")[១] ដែលបានផ្តន្ទាទោស **កាំង ហ្គេកអ៊ាវ** ហៅ **"ឌុច"** ("ជនជាប់ចោទ") ឲ្យមានទោសជាប់ពន្ធនាគារសរុបរួមកំណត់ ៣៥(សាមសិបប្រាំ)ឆ្នាំ ។

២. យោងតាមលិខិតប្រគល់សិទ្ធិចុះថ្ងៃទី១៦ ខែ សីហា ឆ្នាំ ២០១០ របស់ជនជាប់ចោទឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ **"ឌុច"**[២] ដែលបានប្រគល់សិទ្ធិឲ្យសហមេធាវីការពារក្តី ធ្វើការសំរេចក្នុងការប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ របស់អង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ") ទៅអង្គជំនុំជម្រះតុលាការកំពូល("អ.ជ.ត.ក") នៃ អ.វ.ត.ក ។

៣. អនុលោមតាមវិធាន ១០៤(១), ១០៥(១)(ខ) , ១០៦(២) និង ១០៧(៤) នៃវិធានផ្ទៃក្នុង សហមេធាវីជនជាប់ចោទសូមដាក់ការជូនដំណឹងដើម្បីបង្ហាញពីគោលបំណងរបស់ខ្លួន ក្នុងការប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនេះ ។

៤. សហមេធាវីជនជាប់ចោទសូមលើកជាទឡ្ហីករណ៍ថា អង្គជំនុំជម្រះតុលាការកំពូលមានយុត្តាធិការលើបញ្ហាយុត្តាធិការ ដូចដែលមានចែងនៅក្នុងវិធាន ១០៤(១) ជាពិសេស អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តៈ

(ក) កំហុសលើអង្គច្បាប់ ដែលនាំឲ្យមោឃៈភាពសាលក្រមនេះ និង/ឬ

(ខ) កំហុសនៃអង្គហេតុ ដែលបង្កឲ្យសាលក្រមនេះមានភាពមិនយុត្តិធម៌ ។

---

[១] សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, សំណុំរឿងលេខៈ ០០១ /១៨-០៧-២០០៧/អជសដ,អង្គជំនុំជម្រះសាលាដំបូង, ឯកសារលេខៈ E188 ("សាលក្រម"),កថាខណ្ឌទី៦៧៧, ៦៧៨ ។

[២] លិខិតប្រគល់សិទ្ធិជូនសហមេធាវីការពារក្តីចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ របស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" វិធាន១០៦(៣), វិធានផ្ទៃក្នុង ។

00593492



៥. អនុលោមទៅតាមវិធាន ១០៥(៣) កំហុសលើអង្គច្បាប់ និងអង្គហេតុ ត្រូវបានប្រព្រឹត្តឡើងដែលនាំឱ្យសាលក្រមនេះមានភាពមិនយុត្តិធម៌ និង/ឬ នាំឱ្យមោឃៈភាពសាលក្រម ។

## ឧទ្ធរណ៍របស់សហមេធាវីជនជាប់ចោទក្នុងការប្ដឹងសាទុក្ខ

៦. ទឡ្ហីករណ៍របស់សហមេធាវីការពារក្ដីឱ្យជនជាប់ចោទ **កាំង ហ្កេកអ៊ាវ** ហៅ **"ឌុច"** ក្នុងការប្ដឹងសាទុក្ខអំពីអង្គច្បាប់មួយចំនួន ដែលមិនអាចទទួលយកបាន ដូចដែលមានចែងក្នុងកថាខណ្ឌខាងក្រោម[៣] ។

## I. ទឡ្ហីករណ៍ទី១: ការភាន់ច្រឡំអំពីយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង

៧. អង្គជំនុំជម្រះសាលាដំបូង បានសម្រេចដោយមានការភាន់ច្រឡំនៅក្នុងយុត្តាធិការរបស់ខ្លួន ចំពោះឋានានុក្រមបុគ្គលដូចខាងក្រោម៖

**ក.** ការទទួលយក **កាំង ហ្កេកអ៊ាវ** ហៅ **"ឌុច"** ចូលក្នុងយុត្តាធិការរបស់ខ្លួន ដោយពឹងផ្អែកទៅលើភស្តុតាងដាក់បន្ទុកថា ស្ថិតក្នុងយុត្តាធិការពេលវេលា យុត្តាធិការដែនដី យុត្តាធិការបទល្មើស និងមិនបានបង្ហាញឱ្យឃើញច្បាស់លាស់ដោយឥតសង្ស័យ ពីភស្តុតាងដាក់បន្ទុកជាប់ក្នុងយុត្តាធិការលើឋានៈបុគ្គលនោះទេ ដែលការពិត **កាំង ហ្កេកអ៊ាវ** ហៅ **"ឌុច"** មិនស្ថិតនៅក្នុងយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នេះបើផ្អែកទៅលើឋានៈបុគ្គលផ្លូវច្បាប់[៤] ។

**ខ.** ការបកស្រាយច្បាប់ដោយសំអាងលើទំនៀមទម្លាប់អន្តរជាតិ មិនស៊ីនឹងអង្គច្បាប់របស់អ.វ.ត.ក[៥] ការយកប្រព័ន្ធច្បាប់ Common Law មកបកស្រាយជាន់លើប្រព័ន្ធច្បាប់ Civil Law ដែលមានស្រាប់

---

[៣] វិធាន១០៥(៣), វិធានផ្ទៃក្នុង ។

[៤] សាលក្រម, កថាខណ្ឌទី១៣,១៧,១៨,១៩,២០,២១,២៣ ។

[៥] សាលក្រម, កថាខណ្ឌទី២២,២៤,៣០,៣១,៣៣ ។

នៅកម្ពុជា[៦]។ ការបកស្រាយបែបនេះគឺបំពានទៅនឹងមាត្រា២ ចំណុច១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងទៅនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងរយៈពេលនៃកម្ពុជាប្រជាធិបតេយ្យ បំពានលើមាត្រា១ និងមាត្រា២(ថ្មី) នៃច្បាប់ស្ដីពីការបង្កើតអ.វ.ត.ក និងបំពានលើរចនាសម្ព័ន្ធច្បាប់ដែលមានស្រាប់នៅកម្ពុជាតាមប្រព័ន្ធច្បាប់Civil Law ។

**គ.** វាហាក់បីដូចជា យុត្តិធម៌របស់អ្នកឈ្នះផ្ដល់ឱ្យអ្នកចាញ់ ហើយសាលាជម្រះក្ដីនេះ បង្កើតឡើងសំរាប់តែកាត់ទោស **កាំង ហ្គេកអ៊ាវ** ហៅ **"ឌុច"**។ យុត្តាធិការលើឋានានុក្រមចំពោះបុគ្គល មិនត្រូវបានលើកយកមកពិភាក្សាដេញដោលឱ្យច្បាស់លាស់មុននឹងសម្រេចថា **កាំង ហ្គេកអ៊ាវ** ស្ថិតនៅក្នុងយុត្តាធិការរបស់ខ្លួន ដោយគ្រាន់តែលើកសំអាងហេតុថាជាអញ្ញត្រកម្ម ដែលលើកឡើងដោយមេធាវីការពារជនជាប់ចោទថា យឺតពេល[៧]។

## II. ទឡ្ហីករណ៍ទី២: ការភាន់ច្រឡំចំពោះការផ្ដន្ទាទោសដាក់ពន្ធនាគារសរុបរួមកំណត់ ៣៥ឆ្នាំ

៨. អង្គជំនុំជម្រះសាលាដំបូង បានពិនិត្យមើលតែទៅលើយុត្តាធិការលើបទល្មើស យុត្តាធិការពេលវេលា យុត្តាធិការដែនដី ដែលនាំឱ្យគេយល់ឃើញថា សាលាជម្រះក្ដីរបស់អ.វ.ត.ក នេះអាចសម្រេចទោស **កាំង ហ្គេកអ៊ាវ** ហៅ **"ឌុច"** ចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅស-២១ ចំពោះបទល្មើសដែលកំណត់[៨] ដោយមិនបានពិនិត្យអំពីឋានៈផ្លូវច្បាប់របស់**កាំង ហ្គេកអ៊ាវ** ហៅ **"ឌុច"** ចំពោះសាលាជម្រះក្ដី អ.វ.ត.ក ដែលស្ថិតក្នុងភាពជាសាក្សីដ៏មានសក្ដានុពល និង សហការពេញលេញជាមួយសាលាជម្រះក្ដីនោះទេ ។

---

[៦] សាលក្រម, កថាខណ្ឌទី៤៥,៤៨ ។

[៧] វិធាន ៨៧, វិធានផ្ទៃក្នុង ។

[៨] សាលក្រម, កថាខណ្ឌទី៦៧៦,៦៧៧ ។

៩. ការមិនបានពិនិត្យមើលលើយុត្តាធិការចំពោះឋានានុក្រមបុគ្គល ដែលជាការសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ថាជាអញ្ញត្រកម្មដែលលើកឡើងយឺតពេល[៩] វាផ្ទុយនឹងវិធាន៨៧ ស្តីពីភស្តុតាងនៅក្នុងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ។

## សេចក្តីសន្និដ្ឋាន

១០. បណ្តឹងសាទុក្ខនេះ ស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូល៖

**ក.** បដិសេធចោលសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងទាំងស្រុង និងដោះលែង **កាំង ហ្គេកអ៊ាវ** ហៅ **"ឌុច"** ឱ្យមានសេរីភាពឡើងវិញ ។

**ខ.** ចាត់ទុក **កាំង ហ្គេកអ៊ាវ** ហៅ **"ឌុច"** ជាសាក្សី ហើយរយៈពេលឃុំខ្លួនពីថ្ងៃចាប់ខ្លួនរហូតដល់ថ្ងៃសម្រេចសេចក្តីជាចុងក្រោយថាជាការថែរក្សាការពារសាក្សី ។

## សុំរក្សាសិទ្ធិកែប្រែគ្រប់យ៉ាង

| | | | |
|---|---|---|---|
| 24-8-2010 | សហមេធាវីជាតិ<br>មេធាវី **ការ សាវុត្ថ**<br>មេធាវី **កង ឫទ្ធារី** | ភ្នំពេញ | [signatures] |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |

[៩] សាលក្រម, កថាខណ្ឌទី១៤,១១៥ ។